ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៙ * ៚៙

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ : ...៤២៧... ប្រក.សក.បធ

រាជធានីភ្នំពេញ.ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលគ្រឿងចក្រធំៗ

## រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧០៤.១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.៩៤.០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស.៩៤.០៦ ចុះថ្ងៃ ទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រី-រាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.០៣ ចុះថ្ងៃ ទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសេចក្តីត្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

## សម្រេច

**ប្រការ ១** : មជ្ឈមណ្ឌលគ្រឿងចក្រធំៗស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានសាធារណការនៃក្រសួងសាធារណការ និងដឹកជញ្ជូន ហើយដែលមានតួនាទីភារកិច្ចដូចមានចែងក្នុងមាត្រា ១៣នៃអនុក្រឹត្យលេខ ១៤ អនក្រ.បក. ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដូចខាងក្រោម ÷

**១-១ សិក្សាស្រាវជ្រាវធ្វើគំរោង និងស្ថាបនាការងារថ្មី :**

- សិក្សាស្រាវជ្រាវ និងលើកគំរោងស្ថាបនា ផ្លូវ-ស្ពាន
- អនុវត្តការស្ថាបនា ផ្លូវ-ស្ពាន និងការងារជួសជុលធំ
- អន្តរាគមន៍ដល់ការងារជួសជុលបន្ទាន់ ។

**១-២ គ្រប់គ្រង និង ត្រួតពិនិត្យបរិក្ខារ-គ្រឿងចក្រនៅក្រោមអាណាព្យាបាល :**

- រៀបចំ និងផ្សព្វផ្សាយបទដ្ឋានបច្ចេកទេស ក្នុងការប្រើប្រាស់ ថែទាំគ្រឿងចក្រដល់អង្គភាពមូលដ្ឋាន
- គ្រប់គ្រងសំភារៈគ្រឿងចក្រគ្រប់ប្រភេទ ដែលប្រើសំរាប់ការងារសាធារណការ ។

**១-៣ សិក្សា និងរៀបចំបណ្តុះបណ្តាលបុគ្គលិកជំនាញខាងគ្រឿងចក្រ :**

- សិក្សាស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិស្តីពី សុវត្ថិភាពការងារ និងអនាម័យ
- បណ្តុះបណ្តាលជំនាញបើកបរ បញ្ជាគ្រឿងចក្រគ្រប់ប្រភេទ សំរាប់ការងារសាធារណការ

មជ្ឈមណ្ឌលគ្រឿងចក្រធំ១ទទួលបន្ទុកអនុវត្តការងារជំនាញឯកទេសមួយចំនួនទៀតតាមការប្រគល់ភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួង ។

**ប្រការ ២ :** • មជ្ឈមណ្ឌលគ្រឿងចក្រធំ១ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់

• ការិយាល័យចំណុះមជ្ឈមណ្ឌលដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់

• អង្គភាពមូលដ្ឋានមានថ្នាក់ស្មើការិយាល័យចំណុះមជ្ឈមណ្ឌល ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៣ :** មជ្ឈមណ្ឌលគ្រឿងចក្រធំ១ ត្រូវបានបែងចែកជាការិយាល័យ និងអង្គភាពមូលដ្ឋាននៅក្រោមចំណុះដូចខាងក្រោម ÷

**៣-១ ការិយាល័យ ស្ថិតក្រោមចំណុះមជ្ឈមណ្ឌលគ្រឿងចក្រធំ១ :**

- ការិយាល័យ រដ្ឋបាល បុគ្គលិក-ធនធានមនុស្ស
- ការិយាល័យ គណនេយ្យ-ហិរញ្ញវត្ថុ
- ការិយាល័យ ផែនការ-បច្ចេកទេស ។

**៣-២ អង្គភាពមូលដ្ឋានមានថ្នាក់ស្មើការិយាល័យ ស្ថិតក្រោមចំណុះមជ្ឈមណ្ឌលគ្រឿងចក្រធំ១ :**

- មូលដ្ឋាន ស្ថាបនាផ្ទាល់ (RCC)
- អង្គភាព អន្តរាគមន៍ សាធារណការ (IPUW) ។

**ប្រការ ៤ :** តួនាទី និងភារកិច្ចការិយាល័យចំណុះមជ្ឈមណ្ឌលគ្រឿងចក្រធំ១ ÷

**៤-១ ការិយាល័យ រដ្ឋបាល បុគ្គលិក-ធនធានមនុស្ស :**

- គ្រប់គ្រងមន្ត្រីរាជការក្នុងក្របខ័ណ្ឌមជ្ឈមណ្ឌលអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលរាល់កិច្ចការទូទៅរបស់មជ្ឈមណ្ឌលគ្រឿងចក្រធំ១

- គ្រប់គ្រងឯកសាររដ្ឋបាល ធានាប្រសិទ្ធភាព-សុវត្ថិភាព និងចរាចរឱ្យទាន់ពេលវេលា
- គ្រប់គ្រងការងារ សន្តិសុខ សណ្តាប់ធ្នាប់បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌល ហើយបើមានការងារចាំបាច់ផ្សេងទៀត ត្រូវសុំយោបល់ពីថ្នាក់ដឹកនាំមជ្ឈមណ្ឌល និងធ្វើការណែនាំផ្ទាល់ទៅអង្គភាពពាក់ព័ន្ធ
- រៀបចំបែបបទស្នើសុំតម្លើងថ្នាក់មុខតំណែង និងឋានន្តរស័ក្តិដល់មន្ត្រីរាជការ
- ចាត់មន្ត្រីឱ្យចូលរួមវគ្គបណ្តុះបណ្តាលធ្វើកម្មសិក្សា ទស្សនកិច្ច បន្តការសិក្សាក្នុង និងក្រៅប្រទេសតាមការកំណត់របស់ក្រសួង
- រៀបចំបែបបទធានារ៉ាប់រងសង្គមដល់ជនបាត់បង់សមត្ថភាពពលកម្ម និវត្តជន និងមរណជន
- រៀបចំបែងចែកភារកិច្ចដល់មន្ត្រីរាជការ ទៅតាមសមត្ថភាពជំនាញ និងបទពិសោធន៍ការងារ
- ចូលរួមរៀបចំបទប្បញ្ញត្តិស្តីពីសុវត្ថិភាពការងារ និងអនាម័យក្នុងការប្រើប្រាស់គ្រឿងចក្រនៅតាមអង្គភាពមូលដ្ឋាន
- រៀបចំវគ្គបណ្តុះបណ្តាលបើកបរ និងថែទាំគ្រឿងចក្រ
- សរុបរបាយការណ៍ប្រចាំខែ-ត្រីមាស-ឆមាស-ឆ្នាំ អំពីសកម្មភាពការងាររបស់មជ្ឈមណ្ឌលជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល និងក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

**៤-២ ការិយាល័យ គណនេយ្យ-ហិរញ្ញវត្ថុ :**

- គ្រប់គ្រងការងារហិរញ្ញវត្ថុ ក្នុងការស្ថាបនា ផ្លូវ-ស្ពាន
- គ្រប់គ្រង ត្រួតពិនិត្យការប្រើប្រាស់ថវិកាឱ្យបានត្រឹមត្រូវ តាមដីកាចំណូល និងធានាចំណាយ
- កំណត់ខ្ទង់ចំណូល និង ចំណាយតាមច្បាប់ និងបទបញ្ជា
- គ្រប់គ្រងសាច់ប្រាក់ក្នុងបេឡា
- ចូលរួមទទួលខុសត្រូវ អនុវត្តផ្នែកលទ្ធកម្មសាធារណៈក្នុងក្របខ័ណ្ឌរបស់មជ្ឈមណ្ឌល
- កសាងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ចលនវត្ថុ អចលនវត្ថុប្រចាំឆ្នាំ
- សហការត្រួតពិនិត្យកិច្ចការជំរះបញ្ជីទ្រព្យសម្បត្តិរដ្ឋ
- តាមដានតំលៃសំភារៈ គ្រឿងបន្លាស់រថយន្ត គ្រឿងចក្រនៅទីផ្សារ ដើម្បីជាមូលដ្ឋាននៃការរៀបចំថវិកាជួសជុល គ្រឿងចក្រនៅក្នុងអង្គភាព ។
- ធ្វើរបាយការណ៍ប្រចាំខែ-ត្រីមាស-ឆមាស-ឆ្នាំ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

**៤-៣ ការិយាល័យផែនការ-បច្ចេកទេស :**

- ធ្វើផែនការប្រចាំឆ្នាំ ( ស្រាវជ្រាវ និងលើកគំរោង ជួសជុល ផ្លូវ -ស្ពាន តាមលំដាប់អាទិភាពក្នុងក្របខ័ណ្ឌមជ្ឈមណ្ឌលដោយរួមសហការជាមួយនាយកដ្ឋានផែនការ)
- ត្រួតពិនិត្យការងារជួសជុល និងស្ថាបនា ផ្លូវ-ស្ពាន និងគុណភាពសំភារៈសំណង់ នៅតាមការដ្ឋាន
- លើកគំរោងស្នើសុំជំនួយបរទេសតាមផែនការរបស់ក្រសួងដោយរួមសហការជាមួយនាយកដ្ឋានផែនការ
- ធ្វើបញ្ជីប៉ាន់តម្លៃការងារជួសជុល និងស្ថាបនា ផ្លូវ-ស្ពាន ដែលក្រសួងប្រគល់មកឱ្យមជ្ឈមណ្ឌល
- សិក្សាស្រាវជ្រាវ និងរៀបចំបទដ្ឋានបច្ចេកទេសសំណង់សាធារណការ

- រៀបចំ និងផ្សព្វផ្សាយបទដ្ឋានបច្ចេកទេស ក្នុងការប្រើប្រាស់ ថែទាំមធ្យោបាយ គ្រឿងចក្រដល់អង្គភាព-មូលដ្ឋាន
- រៀបចំទុកដាក់ឯកសារបច្ចេកទេស គំនូសប្លង់ ឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព
- ធ្វើរបាយការណ៍ប្រចាំខែ -ត្រីមាស -ឆមាស -ឆ្នាំ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល
- អនុវត្តភារកិច្ចផ្សេងៗ ទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

**ប្រការ ៥** : តួនាទី និងភារកិច្ចរបស់អង្គភាពមូលដ្ឋានចំណុះមជ្ឈមណ្ឌលគ្រឿងចក្រធំៗ

**៥-១ មូលដ្ឋានស្ថាបនាផ្លូវ** Road Construction Center (RCC)

- អនុវត្តការស្ថាបនា ផ្លូវ-ស្ពាន និងការងារជួសជុលធំតាមគំរោងផែនការប្រចាំឆ្នាំ របស់ក្រសួង ដែលមជ្ឈមណ្ឌលប្រគល់ជូន
- បញ្ជូនមន្ត្រីរាជការក្រោមឱវាទឱ្យមកបណ្តុះបណ្តាលមុខជំនាញបច្ចេកទេសបើកបរ និងថែទាំគ្រឿងចក្រ
- គ្រប់គ្រងរថយន្ត គ្រឿងចក្រ និងសំភារៈនានា ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ទទួលខុសត្រូវការងារសន្តិសុខសណ្តាប់ធ្នាប់ ក្នុងមូលដ្ឋានដោយអនុវត្តតាមបទបញ្ជាផ្ទៃក្នុង
- ចូលរួមរៀបចំបញ្ជីសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋ ចលនវត្ថុ អចលនវត្ថុរបស់មជ្ឈមណ្ឌល
- រៀបចំ និងប្រើប្រាស់កម្លាំងពលកម្មឱ្យសមស្របតាមសមត្ថភាពជំនាញ
- រាយការណ៍បន្ទាន់ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល នៅពេលមានគ្រោះថ្នាក់ការងារ
- អនុវត្តគំរោងស្ថាបនា តាមកម្មវិធីការងារដែលបានគ្រោងទុក និងតាមបទដ្ឋាន បច្ចេកទេស ដែលបានកំណត់ក្នុងគំរោង
- ធ្វើរបាយការណ៍ប្រចាំខែ-ត្រីមាស- ឆមាស- ឆ្នាំ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល
- អនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

**៥-២ អង្គភាពអន្តរាគមន៍ សាធារណការ** Intervention Unit of Public Works (IUPW) :

- អន្តរាគមន៍ដល់ការងារជួសជុល ផ្លូវ-ស្ពាន បន្ទាន់ ឬដោយចៃដន្យ ( ការងារឥតគ្រោងទុក ) ដែលមជ្ឈមណ្ឌលប្រគល់ជូន
- ចាត់បញ្ជូនមន្ត្រីរាជការឱ្យមកបណ្តុះបណ្តាលលើមុខជំនាញបើកបរ និងថែទាំគ្រឿងចក្រ
- គ្រប់គ្រងរថយន្ត គ្រឿងចក្រ និងសំភារៈប្រើប្រាស់ ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ទទួលខុសត្រូវការងារសន្តិសុខសណ្តាប់ធ្នាប់ ក្នុងមូលដ្ឋានដោយអនុវត្តតាមបទបញ្ជាផ្ទៃក្នុង
- ចូលរួមរៀបចំបញ្ជីសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋ ចលនវត្ថុ អចលនវត្ថុ របស់មជ្ឈមណ្ឌល
- រៀបចំ និងប្រើប្រាស់កម្លាំងពលកម្មឱ្យសមស្របតាមសមត្ថភាពជំនាញ
- រាយការណ៍ជាបន្ទាន់ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល នៅពេលមានគ្រោះថ្នាក់ការងារ
- ធ្វើរបាយការណ៍ ប្រចាំខែ-ត្រីមាស-ឆមាស-ឆ្នាំ ជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌល
- អនុវត្តភារកិច្ចផ្សេងៗ ទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់ជូន ។

**ប្រការ ៦** : ប្រកាសលេខ៣៨៣ ប្រក សក បច ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលគ្រឿងចក្រធំៗ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧** : នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលគ្រឿងចក្រធំៗ នៃក្រសួងសាធារណការ និង ដឹកជញ្ជូនត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួនតាមខ្លឹមសារនៃប្រកាសនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុន-ចាន់ថុល

**<u>ចម្លងជូន:</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**"ដើម្បីជ្រាបជាពត៌មាន"**

- ដូចប្រការ ៧
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- គ្រប់មន្ទីរសាធារណការខេត្ត-ក្រុង

**"ដើម្បីរក្សាទុក"**

-ឯកសារ-កាលប្បវត្តិ